ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៩០/១៩ - សិប្បកម្មបោះពុម្ព ចុង ហួរ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ គង់ ផល្លៈ
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ អាន វីរៈ

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **សិប្បកម្មបោះពុម្ព ចុង ហួរ**
អាសយដ្ឋាន ៖ ផ្លូវលំ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៥៧០ ៩៧៦
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក តាំង ម៉េង | មេធាវី |
| ២- កញ្ញា ជ័យ សុផល | គណនេយ្យ |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃសិប្បកម្មបោះពុម្ព ចុង ហួរ**
អាសយដ្ឋាន ៖ ផ្លូវលំ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៨៨០ ០៣៩/០១០ ៥៤៨ ៤៩៣
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោកស្រី យ៉ាង សុភ័ណ្ឌ | ប្រធានសហព័ន្ធសហជីពកម្ពុជា |
| ២- លោកស្រី ពាញ គឿន | មន្ត្រីសហព័ន្ធសហជីពកម្ពុជា |
| ៣- លោកស្រី ជៀម គឹមសឿន | ប្រធានសហជីពកម្ពុជា (មូលដ្ឋាន) |
| ៤- លោក អ៊ុក សុខលី | អនុប្រធានសហជីពកម្ពុជា (មូលដ្ឋាន) |

| | |
|---|---|
| ៥- លោក ប៉ាវ សុខា | លេខាសហជីពកម្ពុជា(មូលដ្ឋាន) |
| ៦- កញ្ញា ឌី គីមអ៊ី | ហិរញ្ញិកសហជីពកម្ពុជា(មូលដ្ឋាន) |
| ៧- លោក ជុយ វុឌ្ឍី | កម្មករ |
| ៨- លោក ជា សុខនុន | កម្មករ |
| ៩- លោក សុខ ភារម្យ | កម្មករ |
| ១០- លោក ខុន យឺន | កម្មករ |
| ១១- កញ្ញា ម៉ឹន ចាន់ទី | កម្មការិនី |
| ១២- កញ្ញា អុល សុភី | កម្មការិនី |
| ១៣- កញ្ញា សែម ម៉ៅ | កម្មការិនី |
| ១៤- លោកស្រី នឹន មុំ | កម្មការិនី |
| ១៥- លោកស្រី សឿន សុភា | កម្មការិនី |
| ១៦- លោកស្រី អឿ សេង្ហា | កម្មការិនី |
| ១៧- លោកស្រី យុន លី | កម្មការិនី |
| ១៨- លោកស្រី ស៊ុន សុភត្រា | កម្មការិនី |
| ១៩- លោកស្រី ញឹក គីមលន | កម្មការិនី |
| ២០- លោកស្រី ញឹក គីមលី | កម្មការិនី |
| ២១- លោកស្រី អុល សិលា | កម្មការិនី |
| ២២- លោកស្រី ព្រាប ឡេន | កម្មការិនី |
| ២៣- លោកស្រី ជា សំនៀង | កម្មការិនី |
| ២៤- លោកស្រី ជា ចាន់នុច | កម្មការិនី |
| ២៥- លោកស្រី ឈិត សារុន | កម្មការិនី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីតំណាងកម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់ប្រាំចំណុច ជូនកម្មករ ដែលក្រុមហ៊ុនបានជូនដំណឹងបញ្ឈប់ពីការងារ និងគ្រោងបន្តបញ្ឈប់ទៀត។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា ប្រសិនបើក្រុមហ៊ុនបញ្ឈប់កម្មករនិយោជិតណាម្នាក់ ក្រុមហ៊ុននឹងអនុវត្តទៅតាមច្បាប់ស្តីពីការងារ។

២- ភាគីតំណាងកម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំ ជូនកម្មករនិយោជិត(ក្រុមហ៊ុនគិតខុសកន្លងមក)។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តទៅតាមច្បាប់ស្តីពីការងារ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី ១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃសិប្បកម្មបោះពុម្ព ចុងហួរ លេខ ១០៣៧ ក.ប/អក/វក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៩ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃសិប្បកម្មបោះពុម្ព ចុងហួរ ស្តីពីការទាមទារសុំឱ្យសិប្បកម្មដោះស្រាយលក្ខខណ្ឌការងារចំនួន ៣ ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១ ចំណុច លើការទាមទារចំនួន ៣ ចំណុច។ ចំណុចមិនសះជាចំនួន ២ ដែលនៅសល់ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃសិប្បកម្មបោះពុម្ព ចុងហួរ លេខ ១០៣៧ ក.ប/អក/វក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងផ្សះផ្សានៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក ប៉ុន្តែ សវនាការត្រូវបានលើកពេល តាមការស្នើសុំពីភាគីកម្មករនិយោជិត ដោយមានការឯកភាពពីភាគីនិយោជក និងក្រុមអាជ្ញាកណ្តាល ទៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង១៤ និង ០០ នាទី រសៀល វិញ។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានព្យាយាមស្វះរកនូវអង្គហេតុ និងបានផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត នៅក្នុងសវនាការ។ ភាគីទាំងពីរបានព្រមព្រៀងគ្នាចំនួន ១ ចំណុច គឺចំណុចវិវាទទី១។ ហេតុនេះ ចំណុចមិនសះជាដែលនៅសល់ គឺចំណុចវិវាទទី២។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានកំណត់ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្ដាល ពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

- លិខិតរបស់នាយិកាសិប្បកម្មបោះពុម្ព ចុង ហួរ គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីសំណើសុំបដិសេធចំពោះបញ្ជីឈ្មោះកម្មករ កម្មការិនី ចំនួន ៦២ នាក់ កន្លងមកមិនដែលទាមទារការទូទាត់ប្រាក់បំណាច់ឆ្នាំ និងពុំមានដាក់ភស្តុតាងឱ្យសិប្បកម្ម ចុង ហួរ ចុះថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈរបស់សហជីពកម្ពុជានៃសិប្បកម្មបោះពុម្ព ចុង ហួរ លេខ ២៣៤/១៩ ក.ប/វ.ប.វ.ក ចុះថ្ងៃអង្គារ ៩កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៩។

២- លិខិតលេខ ១១១/១៩ កប/វក ចុះថ្ងៃអង្គារ ៩កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្ពុជានៃសិប្បកម្មបោះពុម្ព ចុង ហួរ ជាអង្គការវិជ្ជាជីវៈមួយដែលបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៣- តារាងគិតលុយកម្មករដែលក្រុមហ៊ុនគិតលុយឱ្យកម្មករ។

៤- លិខិតជូនដំណឹងស្ដីពីការមិនបន្តកិច្ចសន្យាការងារលោកស្រី សែម ម៉ៅ, លោកស្រី ស៊ិន សុភិក្រ, លោកស្រី និន មុំ, លោកស្រី អុល សិលា និងលោកស្រី ថន សុគីន។

៥- តារាងជូនដំណឹងស្ដីពីការបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣០ នាក់។

៦- កាតសំគាល់ខ្លួន និងក្រដាសបើកប្រាក់ខែ។

THE ARBITRATION COUNCIL

៧- លិខិតរបស់ថ្នាក់ដឹកនាំសហជីពកម្ពុជា គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំបញ្ជូនបញ្ជីឈ្មោះកម្មករ កម្មការិនី ចំនួន ៦២ នាក់ ដែលពួកគាត់ចូលរួមទាមទាឱ្យសិប្បកម្មបោះពុម្ព ចុង ហួរ ទូទាត់សងលុយបំណាច់ឆ្នាំនាពេលកន្លងមក ដែលសិប្បកម្មមិនបានអនុញ្ញាតិឱ្យកម្មករឈប់សម្រាក ចុះថ្ងៃអង្គារ ៣កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃ ទី០១ ខែតុលា ឆ្នាំ២០១៩។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅសិប្បកម្មបោះពុម្ព ចុងហួរ លេខ ១០៣៧ ក.ប/អក/វក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅសិប្បកម្មបោះពុម្ព ចុងហួរ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃសិប្បកម្មបោះពុម្ព ចុង ហួរ លេខ ០០៨ ក.ប/អក/លបវ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥០២ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥០៣ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥១០ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥១១ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

សិប្បកម្មបោះពុម្ព ចុងហួរ គឺមានសកម្មភាពចម្បងផ្នែកសិប្បកម្មបោះពុម្ព។ សិប្បកម្មនេះមានបុគ្គលិកកម្មករនិយោជិតសរុបចំនួន ៦៣ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅសិប្បកម្មបោះពុម្ព ចុងហួរ)*។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទូទាត់ប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំ ជូនកម្មករនិយោជិត**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកសងរំលឹកប្រាក់បំណាច់ជួសការឈប់ប្រចាំឆ្នាំ ក្នុងរយៈពេល ៣ឆ្នាំ ចុងក្រោយ (ដោយយកប្រាក់ឈ្នួលគោល និងប្រាក់បន្ទាប់បន្សំមកគណនា) ជូនកម្មករនិយោជិតទាំងអស់។
- ភាគីទាំងពីរទទួលស្គាល់ថា៖
    - ការអនុវត្តនៅក្នុងក្រុមហ៊ុន កម្មករនិយោជិតមិនប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំរបស់ពួកគាត់ទេ ដោយនិយោជកគណនាជាប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំជូនពួកគាត់វិញ។ សម្រាប់ការគណនាប្រាក់បំណាច់នេះ គឺនិយោជកយកតែប្រាក់ឈ្នួលគោលមកគណនាតែប៉ុណ្ណោះ។
    - ការគណនាប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំនេះ គឺមិនមានបង្គាន់ដៃបើកប្រាក់ឈ្នួលនោះទេ។
    - ការទាមទារនេះ គឺសម្រាប់កម្មករនិយោជិតទាំងអស់ដែលកំពុងធ្វើការ។
- ភាគីកម្មករនិយោជិតបានទទួលស្គាល់ថា ច្បាប់ស្តីពីការងារ មិនអនុញ្ញាតឱ្យគណនាប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំជូនកម្មករនិយោជិតដែលកំពុងធ្វើការនោះទេ ប៉ុន្តែ និយោជកឱ្យកម្មករនិយោជិតមកធ្វើការ ដូច្នេះការគណនាប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំនេះ ត្រូវយកប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំមកគណនា។
- ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់កម្មករនិយោជិតបានទេ ដោយសារ ៖
    - កម្មករនិយោជិតបានព្រមព្រៀងជាមួយនឹងនិយោជកដោយផ្ទាល់មាត់ថា ពួកគាត់មកធ្វើការ ហើយនិយោជកទូទាត់ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដោយយកប្រាក់ឈ្នួលគោល មកគណនា។
    - ចាប់ពីឆ្នាំ២០០៣មក ការគណនាប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ គឺយកតែប្រាក់ឈ្នួលគោលមកគណនា ជូនកម្មករនិយោជិតប៉ុណ្ណោះ។
    - យោងតាមមាត្រា ១៦៧ នៃច្បាប់ស្តីពីការងារ គឺមិនអនុញ្ញាតឱ្យគណនាប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំនោះទេ។
    - បើភាគីកម្មករនិយោជិតមិនព្រមទទួលយកការទូទាត់នេះទេ និយោជកអាចអនុញ្ញាតឱ្យពួកគាត់ប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំធម្មតា។
- យោងតាមឯកសាររបស់ភាគីកម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញបញ្ជីឈ្មោះកម្មករ-កម្មការិនី និងស្នាមមេដៃចំនួន ៦២ នាក់ ចូលរួមទាមទារឱ្យសិប្បកម្មបោះពុម្ព ចុងក្រោយ ទូទាត់ប្រាក់បំណាច់ ឆ្នាំ នាពេលកន្លងមក។
- យោងតាមឯកសាររបស់ភាគីនិយោជក ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញភាគីនិយោជកបានបដិសេធ បញ្ជីឈ្មោះ និងស្នាមមេដៃចំនួន ៦២ នាក់ ដែលថា ក្រុមហ៊ុនគិតខុស ប៉ុន្តែ ភាគីនិយោជកពុំបង្ហាញភស្តុតាងគាំទ្រនឹងការបដិសេធរបស់ខ្លួនទេ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

**ចំណុចវិវាទទី ២៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកសងវិលើកប្រាក់បំណាច់ទូទាត់ជួសការឈប់ប្រចាំឆ្នាំក្នុងរយៈពេល៣ ឆ្នាំ ចុងក្រោយ ដោយយកប្រាក់ឈ្នួលគោល និងប្រាក់បន្ទាប់បន្សំមកគណនា ជូនកម្មករនិយោជិតទាំងអស់**

នៅថ្ងៃជំទាស់ឯកសារភាគីនិយោជកបានដាក់លិខិតសុំបដិសេធបញ្ជីឈ្មោះកម្មករកម្មការិនី ចំនួន ៦២ នាក់ ដោយហេតុថា កន្លងមកមិនដែលទាមទារការទូទាត់ប្រាក់បំណាច់ឆ្នាំនោះទេ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដែលធ្វើការអះអាង ឬចោទប្រកាន់ គឺមានបន្ទុកភស្តុតាង។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៧៩/០៥-អេវើហ្គ្រីន, លេខ ១០១/០៨-ជីឌីអឹម ហេតុផលនៃចំណុចវិវាទទី១ និងទី២, លេខ ១៦៨/០៩-ទឹកថ្លា ផ្លាហ្សា ហេតុផលនៃចំណុចវិវាទទី២, លេខ ១១៥/១០-ជី-ហ្វម៉ូស ហេតុផលនៃចំណុចវិវាទទី១៨ និងលេខ ១៤៨/១១-ដាយ យ៉ាំង, លេខ ២៧៦/១៥-មិត្តភាព ហ្គាមិន ហេតុផលនៃចំណុចវិវាទទី១)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានបដិសេធការទាមទារ ឬច្រានចោលការអះអាងរបស់ភាគីវិវាទ ប្រសិនបើភាគីដែលធ្វើការទាមទារ ឬធ្វើការអះអាងនោះ មិនមានមូលដ្ឋានគ្រប់គ្រាន់ ឬភស្តុតាងជាក់លាក់ ដើម្បីគាំទ្រនូវការទាមទារ ឬការអះអាងរបស់ខ្លួន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦៣/០៤-សាញ វ៉ែល ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៩/០៦-សៅធ៍បាយ ហេតុផលនៃចំណុចវិវាទទី៥, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៤, លេខ ៥១/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣ និងលេខ ០៣២/១៦-អ៊ីជើនិធី ក្លូបិល ស្តុតជីង (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ យល់ស្របនិងការទទួលនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗដែរ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីនិយោជកមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ក្នុងការបញ្ជាក់ថា កម្មករកម្មការិនីចំនួន ៦២ នាក់ មិនបានទាមទារការទូទាត់ប្រាក់បំណាច់ឆ្នាំនោះទេ។ ហេតុនេះ ក្រុមក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការពិចារណាលើលិខិតជំទាស់របស់ភាគីនិយោជក។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាបន្តទៀតថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់បំណាច់ទូទាត់ជួសការឈប់ប្រចាំឆ្នាំក្នុងអំឡុងពេលដែលកម្មករនិយោជិតកំពុងធ្វើការដែរ ឬទេ?

កថាខណ្ឌទី២ មាត្រា ១៦៧ នៃច្បាប់ស្តីពីការងារ ចែងថា៖ *"ក្នុងករណីដែលមានផ្តាច់ ឬចប់កិច្ចសន្យាមុន ដែលកម្មករនិយោជិតបានទទួលសិទ្ធិឈប់សំរាកនោះ ត្រូវសងប្រាក់បំណាច់ទៅកម្មករនិយោជិតនោះតាមកំរិតកំណត់ក្នុងមាត្រា ១៦៦ ខាងលើ។"*។

លើសពីនេះ កថាខណ្ឌទី៣ នៃមាត្រា ១៦៧ ដដែលនេះ ចែងថា៖ *"ក្រៅពីករណីនេះអនុសញ្ញាឯណាដែលមានគ្រោងឱ្យប្រាក់បំណាច់ ដោយទូទាត់សំរាប់ជួសការឈប់សំរាក ព្រមទាំងការព្រមព្រៀងស្តីពីការបោះបង់ ឬមិនព្រមប្រើសិទ្ធិឈប់សំរាកប្រចាំឆ្នាំ ត្រូវទុកជាមោឃៈ ហើយគ្មានហេតុផលអ្វីទាំងអស់ ។"*។

ផ្អែកលើខ្លឹមសារនៃមាត្រា ១៦៧ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ ជូនកម្មករនិយោជិតអាចធ្វើទៅបានតែនៅពេលដែលមានការបញ្ចប់ ឬកាត់ផ្តាច់ទំនាក់ទំនងការងាររបស់កម្មករនិយោជិត និងនិយោជកតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ច្បាប់ស្តីពីការងារបានហាមឃាត់ការផ្តល់ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ក្នុង

អំឡុងពេលដែលនិយោជក និងកម្មករនិយោជិតនៅតែបន្តមានទំនាក់ទំនងគតិយុត្តិជាកិច្ចសន្យាការងារជាមួយគ្នានោះឡើយ។

ដោយឡែក ការអនុវត្តសព្វថ្ងៃរបស់ក្រុមហ៊ុននេះ គឺនិយោជកបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ជូនកម្មករនិយោជិត ទោះបីជានិយោជកនៅតែបន្តកិច្ចសន្យាការងារ ជាមួយកម្មករនិយោជិត ក៏ដោយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តរបស់និយោជកខាងលើនេះ គឺជាការអនុវត្តផ្ទុយទៅនឹងមាត្រា ១៦៧ នៃច្បាប់ស្តីពីការងារ។ ហេតុនេះ និយោជកមិនត្រូវបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ជូនកម្មករនិយោជិតក្នុងអំឡុងពេលដែលកិច្ចសន្យាការងាររបស់ពួកគាត់ ជាមួយនិយោជកនេះនៅតែមានអនុភាពនោះឡើយ ហើយនិយោជកគួរតែអនុញ្ញាតឱ្យកម្មករនិយោជិតប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំនោះ។

ផ្អែកតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់ភាគីកម្មករនិយោជិតមិនមានមូលដ្ឋានគាំទ្រដោយច្បាប់ទេ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនោះយល់ឃើញថា៖ *"ចំពោះការទាមទារ ឱ្យក្រុមហ៊ុនទូទាត់ប្រាក់បំណាច់ជួសការឈប់សំរាកប្រចាំឆ្នាំ គឺជាការទាមទារផ្ទុយនឹងស្មារតីនៃមាត្រា ១៦៧ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧។ ដូច្នេះ ការទាមទារនេះមិនសមហេតុសមផល និងមិនត្រឹមត្រូវឡើយ"។ ( សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៩៤/០៤-អុីជីណិជី ហេតុផលនៃចំណុចវិវាទទី២, លេខ ៤៥/០៥-ប៊ី អែន អិន ហេតុផលនៃចំណុចវិវាទទី១, លេខ ៨៨/១២-មែកណេតជ័ហ្វិតវ៉េ ហេតុផលនៃចំណុចវិវាទទី៦ និង លេខ ៧៣/១៣-យ៉ាក ជីន ហេតុផលនៃចំណុចវិវាទទី៨)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿង ខាងលើដែរ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកសងរំលឹកប្រាក់បំណាច់ទូទាត់ជួសការឈប់ប្រចាំឆ្នាំក្នុងរយៈពេល ៣ឆ្នាំ ចុងក្រោយ ដោយយកប្រាក់ឈ្នួលគោល និងប្រាក់បន្ទាប់បន្សំមកគណនា ជូនកម្មករនិយោជិតទាំងអស់។

យោងតាមការបង្ហាញកស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច

**ចំណុចវិវាទទី ២ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកសងរំលឹកប្រាក់បំណាច់ទូទាត់ជួសការឈប់ប្រចាំឆ្នាំក្នុងរយៈពេល ៣ឆ្នាំ ចុងក្រោយ ដោយយកប្រាក់ឈ្នួលគោល និងប្រាក់បន្ទាប់បន្សំមកគណនា ជូនកម្មករនិយោជិតទាំងអស់។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ១៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លៈ**

ហត្ថលេខា ៖ ------------------------------